ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៣៨៩៥
ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៦

សំណុំរឿងជំនុំជម្រះ
លេខ ៨០៣០
ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦

សាលក្រមព្រហ្មទណ្ឌ
លេខ ១១ "ក្រ២វ"
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៧

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧
វេលាម៉ោង ០៨ព្រឹក ដោយមានសមាសភាពៈ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted]អនុប្រធានសាលាដំបូងរាជធានីភ្នំពេញជាប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៩៥ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ដែលមានជនជាប់ចោទៈ

ឈ្មោះ [redacted]ភេទស្រី អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ ស្ត្រីរកស៊ីផ្លូវភេទ ទីកន្លែងកំណើតនៅសង្កាត់បឹងព្រលិត ខណ្ឌ៧មករា ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ កម្រិតវប្បធម៌ មិនចេះអក្សរ មានទីលំនៅមុនពេលចាប់ខ្លួននៅផ្ទះលេខ ១៥ ផ្លូវលេខ ៣០០ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ស-ម្តាយឈ្មោះ [redacted] នៅលីវ ជានិតិជន។

ឃាត់ខ្លួន នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦។

ឃុំខ្លួន នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦។

ដោយមានលោ[redacted]មេធាវីការពារសិទ្ធិ។

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E០ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **សុខ ទិមុល** ភេទប្រុស អាយុ ២៩ឆ្នាំ មានអាសយដ្ឋាននៅផ្ទះលេខ ១៨១E៣ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ។



Scanned by CamScanner

## អង្គហេតុ

កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ នៅចំណុចផ្ទះលេខ ១៤១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ[redacted] បានកាត់សោរទ្វាផ្ទះ លួចយកសម្ភារៈរបស់ជនរងគ្រោះឈ្មោះ[redacted]ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែប្រពន្ធរបស់ជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកឆោឡោ ហើយឈ្មោះ[redacted] រត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

បានឃើញ របាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៨ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣១៦៨ អ.យ.ធ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៨១២០ "ផ" ជ.ជ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៦ របស់ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ។

## នារពេលសវនាការ

ជនជាប់ចោទឈ្មោះ[redacted]បានឆ្លើយថា: កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ខ្លួនបានជិះម៉ូតូឌុបមកឈប់នៅមុខផ្ទះលេខ ១៤១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ហើយខ្លួនក៏ចូលទៅកាត់សោរទ្វាផ្ទះរបស់គេ លួចយកបានលេបថបចំនួន ០១គ្រឿង និងទូរស័ព្ទចំនួន ០២គ្រឿង ពេលកំពុងធ្វើសកម្មភាពនោះ ស្រាប់តែម្ចាស់គេភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកឆោឡោ ហើយខ្លួនរត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ខ្លួនប្រព្រឹត្តតែម្នាក់ឯងទេ គ្មានបក្ខពួកឡើយ។

តាមអំណានចម្លើយជនរងគ្រោះនិងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ពេលយប់ ក្រុមគ្រួសារខ្លួនបានចាក់សោរផ្ទះចូលដេក លុះដល់ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ស្រាប់តែប្រពន្ធខ្លួនបានស្រែកឆោឡោថាមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ពេលនោះជនសង្ស័យក៏រត់ចុះមកក្រោម ហើយត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។ ចំពោះសម្ភារៈដែលមានចោរលួចមានទូរស័ព្ទដៃ ០២គ្រឿង ម៉ាកសាំស៊ុង ចំនួន ០១គ្រឿង និងអាហ្វូនចំនួន ០១គ្រឿង , ឡេបថបចំនួន ០១គ្រឿង និងខ្សែកផ្លាកទិនចំនួន ០១ខ្សែ តម្លៃចំនួន ១៨០ (មួយរយប៉ែតសិប)ដុល្លារអាមេរិក ហើយខ្លួនទទួលបានទូរស័ព្ទដៃ និងឡេបថប មកប្រើប្រាស់វិញហើយ តែខ្សែករកមិនឃើញ។ សំណូមពរសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ និងសុំទាមទារថ្លៃខ្សែកដែលបាត់បង់ចំនួន ១៨០ (មួយរយប៉ែតសិប)ដុល្លារអាមេរិក។

តាមអំណានចម្លើយសាក្សីឈ្មោះ[redacted]នៅចំពោះមុខចៅក្រមស៊ើបសួរថា: កាលពីថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ពេលយប់ ក្រុមគ្រួសារខ្លួនបានចាក់សោរផ្ទះចូលដេក លុះដល់ថ្ងៃទី ១៣

ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ស្រាប់តែខ្លួនឃើញមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ខ្លួនក៏ស្រែកឆោឡោថាមានចោរចូលលួចយកសម្ភារៈក្នុងផ្ទះ ពេលនោះជនសង្ស័យក៏រត់ចុះមកក្រោម ក៏ត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

តាមអំណានចម្លើយសាក្សីឈ្មោះ [redacted] នៅចំពោះមុខចៅក្រមស៊ើបសួរថាៈ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ ពេលខ្លួនកំពុងដេក ស្រាប់តែឮសម្លេងស្រែកឆោឡោថាមានចោរគាស់ផ្ទះលួចយកសម្ភារៈ ខ្លួនក៏ក្រោកឡើងឃើញមានមនុស្សស្រីម្នាក់កំពុងកាន់ទូរសព្ទដៃរបស់ប្អូនស្រីខ្លួន ហើយឃើញគៀបលេបផបជាប់ភ្លៀក ខ្លួនស្ទុះទៅចាប់ជននោះ តែជនសង្ស័យក៏រត់ចុះមកក្រោម ក៏ត្រូវប្រជាជនឃាត់ខ្លួនប្រគល់ឲ្យសមត្ថកិច្ចតែម្តង។

តាមអំណានកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា បានបញ្ជាក់ថាៈ បានដំណើរការធ្វើកំណត់ហេតុចាប់យកវត្ថុតាងពីឈ្មោះ [redacted] ភេទស្រី អាយុ ១៦ឆ្នាំ រួមមានកន្រ្តៃសម្រាប់កាត់ដែកចំនួន ០១ដើម មានដងពណ៌បៃតង និងស្នាប់ដៃជ័រ ពណ៌ខ្មៅ , ផ្លែឈើសម្រាប់អាដែកចំនួន ០១ដើម , កូនកន្រ្តៃដងជ័រ ពណ៌ខៀវ ចំនួន ០១ , កូនកន្រ្តៃដែកចំនួន ០១ , មេសោរម៉ាកស្វឡេច ពណ៌មាស កាត់ដាច់ ចំនួន ០១ , ទូរសព្ទដៃម៉ាក ខេមហ្វូន ចំនួន ០១គ្រឿង , ទូរសព្ទដៃ ០២គ្រឿង សាំសុង ចំនួន ០១គ្រឿង និងអាយហ្វូនចំនួន ០១គ្រឿង និងឡេបថបចំនួន ០១គ្រឿង។

តាមអំណានរបាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៤ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា បានបញ្ជាក់ថាៈ យោងតាមរបាយការណ៍លេខ ០៧/២០១៦ រ.ប.ក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted] កំណត់ហេតុស្តាប់ការបំភ្លឺរបស់កសិណសាក្សី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់សាក្សីឈ្មោះ [redacted] និងឈ្មោះ [redacted] , កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ឈ្មោះ [redacted] , កំណត់ហេតុប្រគល់ និងទទួលជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុសរុបនៃការឃាត់ខ្លួនជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , ពាក្យស្នើសុំសម្ភារៈ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , កំណត់ហេតុប្រគល់សម្ភារៈ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ , រូបថតប្រគល់សម្ភារៈឲ្យជនរងគ្រោះ និងរូបថតជនសង្ស័យ សន្និដ្ឋានថា ជនសង្ស័យឈ្មោះ [redacted] ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស (គាស់ទម្លុះទម្លាយ) យកសម្ភារៈរបស់ជនរងគ្រោះ នៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោង ០៣:១០នាទី ទៀបភ្លឺ ប្រាកដមែន។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាសូមតម្កល់ការចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។



Scanned by CamScanner

### សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា សុំឲ្យតុលាការសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួន។

### សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted]បាននិយាយសម្តីចុងក្រោយថា: សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួន។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាងនានា

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

### សំអាងហេតុ

១.កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ វេលាម៉ោងប្រហែល ០៣:១០នាទី ទៀបភ្លឺ នៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោស មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទឈ្មោះ [redacted] បានកាត់សោរទ្វាផ្ទះ លួចយកសម្ភារៈរបស់ជនរងគ្រោះឈ្មោះ [redacted] លកំពុងធ្វើសកម្មភាពនោះ ស្រាប់តែប្រពន្ធរបស់ជនរងគ្រោះភ្ញាក់ដឹងខ្លួនទាន់ ក៏ស្រែកឆោឡោ ហើយឈ្មោះ [redacted] រត់ចុះមកក្រោម ក៏ត្រូវប្រជាជនចាប់ខ្លួនប្រគល់ឲ្យសមត្ថកិច្ច ប្រាកដមែន។

២.នាពេលចុះប្រតិបត្តិការឃាត់ខ្លួនជនជាប់ចោទ សមត្ថកិច្ចដកហូតបានកន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម មានដងពណ៌ខៀវតង និងស្នាប់ដៃជ័រ ពណ៌ខ្មៅ , ផ្លែរណាសម្រាប់អាដែកចំនួន ០១ដើម , កូនកន្ត្រៃដងជ័រ ពណ៌ខៀវ ចំនួន ០១ , កូនកន្ត្រៃដែកចំនួន ០១ , មេសោរម៉ាកស្ទេចពណ៌មាស កាត់ដាច់ ចំនួន ០១ , ទូរសព្ទដៃម៉ាក ខេមហ្វូន ចំនួន ០១គ្រឿង , ទូរសព្ទដៃ ០២គ្រឿង សាំសុង ចំនួន ០១គ្រឿង , អាយហ្វូនចំនួន ០១គ្រឿង និងឡេបថបចំនួន ០១គ្រឿង មានដូចក្នុងកំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ សីហា ឆ្នាំ ២០១៦ របស់អធិការដ្ឋានខណ្ឌ៧មករា។

៣.តាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] មានភាពស៊ីចង្វាក់ទាំងស្រុងជាមួយ:

ក.ពាក្យបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ខ.កំណត់ហេតុបណ្តឹង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

គ.កំណត់ហេតុស្តាប់ការបំភ្លឺរបស់កសិណសាក្សី ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឃ.កំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦



Scanned by CamScanner

ង.កំណត់ហេតុប្រគល់ និងទទួលជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ច.កំណត់ហេតុចាប់យកវត្ថុតាង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឆ.កំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ជ.កំណត់ហេតុសរុបនៃការឃាត់ខ្លួនជនសង្ស័យ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ឈ.របាយការណ៍លេខ ០៧/២០១៦ រ.ប.ក ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦

ញ.របាយការណ៍សំយោគលេខ ៨១/១៦ រ.ប.ក ចុះថ្ងៃទី ១៥ សីហា ឆ្នាំ ២០១៦ របស់មន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឲ្យជឿបានថាជនជាប់ចោទឈ្មោះ [redacted]ពិតជាបានប្រព្រឹត្តអំពើ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ ប្រាកដមែន។

៤.ជនជាប់ចោទឈ្មោះ [redacted]ភេទស្រី អាយុ ១៦ឆ្នាំ ជាអនីតិជន ដែលពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាខាងស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាក ដែលកើតចេញពីអំពើប្រព្រឹត្តរបស់ខ្លួន ដោយដឹងយ៉ាងច្បាស់ថាពុំមានសិទ្ធិណាមួយតាមច្បាប់ក្នុងការប្រព្រឹត្តអំពើទុច្ចរិត ប៉ុន្តែនៅតែប្រព្រឹត្តដោយចេតនាទុច្ចរិត ដែលច្បាប់បានកំណត់ថាជាបទល្មើសព្រហ្មទណ្ឌនិងត្រូវផ្តន្ទាទោស តែដោយជនជាប់ចោទជាអនិតិជន គប្បីពិចារណាទៅលើមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

៥.សកម្មភាពប្រព្រឹត្តរបស់ជនជាប់ចោទបានបញ្ជាក់យ៉ាងច្បាស់ពីចេតនាទុច្ចរិតក្នុងការលួចយកទ្រព្យសម្បត្តិអ្នកដទៃ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួនប្រាកដមែន។

៦.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងទ្រព្យសម្បត្តិរបស់បុគ្គលឯកជន ដែលច្បាប់បានហាមឃាត់។

៧.សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលដ្ឋានគ្រប់គ្រាន់ ដើម្បីបញ្ជាក់អំពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ ដែលតុលាការគប្បីពិចារណា និងសម្រេច។

៨.សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ សុំឲ្យតុលាការបន្ធូរបន្ថយទោសដល់កូនក្តីនោះ គប្បីតុលាការពិចារណា។

៩.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted]ភេទស្រី អាយុ ១៦ឆ្នាំ ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១E₀ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ , ១៦០ នៃក្រមព្រហ្មទណ្ឌ។

១០.វត្ថុចាប់យក មានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យកលេខ ១០៣៧ វ.ត ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ គឺទូរសព្ទដៃចំនួន ០១គ្រឿង ម៉ាកខេមហ្វូន ពណ៌ទឹកប្រាក់ (ចាស់ , ខូច) , កន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម , ផ្លែរណាចំនួន ០១ , កូនរន្ត្រៃចំនួន ០២ និងមេសោរស្វឡិចកាត់ជាច់ចំនួន ០១ គប្បីសម្រេចរឹបអូស តាមមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ។



Scanned by CamScanner

១១.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]ានទទួលទូរសព្ទ័ដៃ ០២គ្រឿង ម៉ាកសាំស៊ុង ចំនួន ០១គ្រឿង និងអាហ្វូនចំនួន ០១គ្រឿង , ឡេបថបចំនួន ០១គ្រឿង វិញហើយ តាមកំណត់ហេតុប្រគល់ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលមិត្តភាព គប្បីតុលាការពុំលើកមកពិចារណា។

១២.ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងទាមទារថ្លៃខ្សែកដែលបាត់បង់ចំនួន ១៨០ (មួយរយប៉ែតសិប)ដុល្លាអាមេរិក គប្បីតុលាការសម្រេចតាមការជាក់ស្តែង។

១៣.សំដីចុងក្រោយរបស់ជនជាប់ចោទ បានសុំឲ្យតុលាការបន្ធូរបន្ថយទោស គប្បីតុលាការពិចារណា។

**ហេតុដូច្នេះសម្រេច**

១-ផ្តន្ទាទោសឈ្មោះ [redacted] ភេទស្រី អាយុ ១៦ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ **០២ (ពីរ)ឆ្នាំ**

ពីបទ **លួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្ទះលេខ ១៨១$E_0$ ផ្លូវលេខ ១២៨ ភូមិ ០៨ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៦ តាមមាត្រា ៣៥៣ , ៣៥៧ , ១៦០ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យជនជាប់ចោទឈ្មោះ [redacted]មទាំងអាណាព្យាបាលសងសំណងការខូចខាតចំនួន ១៧០ (មួយរយចិតសិប)ដុល្លាអាមេរិក ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]

៣-វត្ថុចាប់យក ដែលត្រូវរឹបអូស តាមមាត្រា ៦២ , ៦៣ នៃក្រមព្រហ្មទណ្ឌ គឺទូរសព្ទ័ដៃចំនួន ០១គ្រឿង ម៉ាកខេមហ្វូន ពណ៌ទឹកប្រាក់ (ចាស់ , ខូច) , កន្ត្រៃសម្រាប់កាត់ដែកចំនួន ០១ដើម , ផ្លែរណាចំនួន ០១ , កូនកន្ត្រៃចំនួន ០២ និងមេសោរសូឡិចកាត់ដាច់ចំនួន ០១។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧ ចំពោះមុខជនជាប់ចោទ , មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ , កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

បើកសិទ្ធិប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧

**ក្រឡាបញ្ជី**

[redacted]



Scanned by CamScanner